រាជធានីភ្នំពេញ ថ្ងៃទី27 ខែកុម្ភៈ៖ នៅក្នុងបេសកកម្មរបស់ខ្លួនដើម្បីជំរុញឱ្យមានការអនុវត្តធុរកិច្ចប្រកបដោយការទទួលខុសត្រូវ និងដើម្បីលើកកម្ពស់ការយល់ដឹងបន្ថែមទៀតអំពីវិធីទប់ស្កាត់អំពើហិង្សា និងការបៀតបៀនផ្អែកលើយេនឌ័រ (GBVH) នៅកន្លែងធ្វើការ មណ្ឌលអាជីវកម្មមានទំនួលខុសត្រូវ (RBH) របស់សភាពាណិជ្ជកម្មអឺរ៉ុប ដោយសហការជាមួយសមាគមសហគ្រិនស្ត្រីកម្ពុជា (CWEA) បានរៀបចំកិច្ចប្រជុំមួយដែលមានឈ្មោះថា Breakfast Talk ស្តីពី “*ការទប់ស្កាត់ការ បៀតបៀននៅកន្លែងធ្វើការ៖ ការលើកកម្ពស់ការយល់ដឹង គោលការណ៍ណែនាំ និងការអនុវត្តល្អៗ*”។

យោងតាមឯកសារពិភាក្សាកាលពីពេលថ្មីៗដែលបោះពុម្ពផ្សាយដោយអង្គការពលកម្មអន្តរជាតិ (ILO) ការបៀតបៀនផ្លូវភេទនៅកម្ពុជា គឺជាបាតុភាពរីកសាយភាយនៅកន្លែងធ្វើការជាច្រើនដែលមានស្ត្រីប្រមាណ 40-60% និងបុរស 10% បានរងការបៀតបៀននៅកន្លែងធ្វើការ។ ដូច្នេះ តាមរយៈធាតុចូល និងការពិភាក្សារបស់អ្នកជំនាញ កិច្ចប្រជុំនោះមានគោលដៅលើកកម្ពស់ការយល់ដឹងអំពីការទប់ស្កាត់ GBVH នៅកន្លែងធ្វើការដោយចែករំលែកគំនិតផ្តួចផ្តើម និងការអនុវត្តដែលមានស្រាប់ ព្រមទាំងការកំណត់អនុសាសន៍សម្រាប់វិធានការនាពេលអនាគតដើម្បីកាត់បន្ថយការបៀតបៀនទាំងនោះ និងទប់ស្កាត់ការកើតឡើងជាបញ្ហាធ្ងន់ធ្ងរផងដែរ។

កិច្ចប្រជុំនោះមានតំណាងមកពីក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) ក្រសួងកិច្ចការនារី (MOWA) គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC/ILO) គម្រោង Deutsche Gesellschaft fur Internationale Zusammenarbeit (GIZ – FABRIC Cambodia) និងតំណាងមកពីវិស័យឯកជន។

កិច្ចប្រជុំនោះត្រូវបានថ្លែងសុន្ទរកថាបើកពីសំណាក់លោកស្រី Sara Monti មន្ត្រីសម្របសម្រួលនៃមជ្ឈមណ្ឌល RBH ដែលបានលើកឡើងថា “ការទប់ស្កាត់ និងកាត់បន្ថយការបៀតបៀនផ្លូវភេទនៅ

កន្លែងធ្វើការមិនត្រឹមតែជាអាជ្ញាបញ្ហាផ្នែកសីលធម៌ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងជាសមាសធាតុសំខាន់នៃធុរកិច្ចដែលមានទំនួលខុសត្រូវ និងដោយចីរភាពផងដែរ"។

លោកជំទាវ ជា រដ្ឋា តំណាងមកពីសមាគមសហគ្រិនស្ត្រីកម្ពុជា (CWEA) បានសង្កត់ធ្ងន់ទៅលើតម្រូវការឱ្យមានស្ត្រីកាន់តែច្រើនថែមទៀតនៅក្នុងមុខតំណែងជួរមុខផ្នែកធុរកិច្ច និងសារៈសំខាន់នៃការពង្រឹងចំណេះដឹងប្រជាជនអំពីសិទ្ធិរស់នៅ និងធ្វើការដោយគ្មានការបៀតបៀនផ្លូវភេទគ្រប់ទម្រង់ទាំងអស់ ហើយក៏លើកទឹកចិត្តដល់ជនរងគ្រោះឱ្យបញ្ចេញមតិយោបល់របស់ខ្លួនឱ្យកាន់តែមានលក្ខណៈជាប្រព័ន្ធផងដែរ។

លោកជំទាវ សុវណ្ណ វណ្ណារតន៍ រដ្ឋលេខាធិការក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងលោកស្រី ស ស៊ីណែត នាយករងនៃនាយកដ្ឋានអភិវឌ្ឍន៍សង្គមនៃក្រសួងកិច្ចការនារី បានគូសបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការដោះស្រាយ GBVH នៅកន្លែងធ្វើការ និងវិធានការដែលនឹងត្រូវអនុវត្ត ដើម្បីទប់ស្កាត់ និងដោះស្រាយបញ្ហានោះដូចជា កម្មវិធីផែនការសកម្មភាពជាតិស្តីពីអំពើហិង្សាប្រឆាំងស្ត្រី (NAPVAW II) (ឆ្នាំ2019-2023)។

លោក Arron Goldman ប្រធានកម្មវិធីនៃ BFC បានចែករំលែកគោលការណ៍ណែនាំដែលទើបនឹងបោះពុម្ពផ្សាយកាលពីពេលថ្មីៗដែលបានលើកឡើងអំពី GBVH ក្នុងឧស្សាហកម្មសម្លៀកបំពាក់ និងវាយនភណ្ឌដោយមានគោលបំណងផ្តល់ការណែនាំជាក់ស្តែងជាជំហានៗនៅក្នុងការប្រយុទ្ធប្រឆាំងអំពើហិង្សាតាមយេនឌ័រសម្រាប់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យនោះ។

កិច្ចប្រជុំនោះក៏មានការចូលរួមពីតំណាងជាច្រើនមកពីវិស័យឯកជនដែលទទួលខុសត្រូវយ៉ាងសំខាន់ក្នុងការបង្កើតកន្លែងធ្វើការមានសុវត្ថិភាព និងគួរឱ្យគោរពសម្រាប់និយោជិតរបស់ខ្លួនរួមទាំងការទប់ស្កាត់ការបៀតបៀនផ្លូវភេទផងដែរ។

ក្រុមហ៊ុនវិស័យឯកជនដូចជាក្រុមហ៊ុន Danone (តំណាងដោយលោកស្រី ង៉ែត គុណធីតា ប្រធានផ្នែកកិច្ចការ និងទំនាក់ទំនងសាធារណៈ) និងក្រុមហ៊ុនច្បាប់ដូចជាក្រុមហ៊ុន Bun & Associates (តំណាងដោយលោក Antoine Fountaine ដៃគូស្ថានិក) បានចែករំលែកបទពិសោធន៍របស់ខ្លួន និងបង្ហាញពីការអនុវត្តល្អៗសម្រាប់ការដោះស្រាយបញ្ហាបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការដូចជា ក្រុមហ៊ុន Danone បានចែករំលែកចំណុចសំខាន់ៗមួយចំនួននៃកម្មវិធីសកលរបស់ខ្លួនពាក់ព័ន្ធនឹងបញ្ហានេះ។

នៅអំឡុងកិច្ចប្រជុំគណៈកម្មាធិការវិនិច្ឆ័យ តំណាងមកពី CWEA, the Women Empowerment House (WE House) និង the Women Union Network (WUN) បានបញ្ជាក់ច្បាស់អំពីសារៈសំខាន់នៃការលើកកម្ពស់សមភាពយេនឌ័រជាពិសេសនៅកម្រិតសហជីព និងលើកកម្រិតការយល់ដឹងអំពីប្រធានបទនេះនៅតាមគ្រប់កម្រិតទាំងអស់នៅកន្លែងធ្វើការចាប់ពីនិយោជិតផ្ទាល់រហូតដល់ថ្នាក់គ្រប់គ្រងកំពូល។

កិច្ចប្រជុំនោះបានដើរតួនាទីជាឱកាសនៅកម្ពុជាសម្រាប់ការប្រមូលផ្តុំអ្នកជំនាញមកពីវិស័យផ្សេងៗគ្នា និងចែករំលែកការអនុវត្តល្អៗដែលមានស្រាប់ដែលអនុម័តដោយរដ្ឋាភិបាល និងវិស័យឯកជនក្នុងការដោះស្រាយបញ្ហាទាំងនេះដែលនៅតែកើតមាននៅកន្លែងធ្វើការ។ បន្ថែមលើការលើកឡើងខាងលើ គំនិតផ្តួចផ្តើម RBH នេះ មានគោលដៅកំណត់ និងផ្តល់អនុសាសន៍ថ្មីៗដែលទទួលបានពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដើម្បីបន្តប្រយុទ្ធប្រឆាំងអំពើហិង្សា និងការបៀតបៀនតាមយេនឌ័រតាមគ្រប់រូបនៅកន្លែងធ្វើការ។ អនុសាសន៍ដែលបានបញ្ជាក់ជាថ្មីជាច្រើន រួមមានតម្រូវការនៅតែមានខ្ពស់ក្នុងការលើកកម្ពស់កម្រិតអប់រំ និងព័ត៌មាននៅក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ចំពោះបញ្ហានោះ។ ក្រៅពីនេះ

តម្រូវការឱ្យមាននីតិវិធីសាស្ត្រច្បាប់លាស់ និងមានស្តង់ដារក្នុងករណី GBVH ត្រូវគូសបញ្ជាក់ជាការគាំទ្រ អនុវត្តពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ និងមានតម្លាភាព ចំណែករចនាសម្ព័ន្ធរាយការណ៍មានសារៈសំខាន់ នៅក្នុងការបង្កើនទំនុកចិត្តចំពោះដំណើរការដោះស្រាយ ព្រមទាំងសង្កត់ធ្ងន់អំពីការមិនអត់ឱនចំពោះ ការរំលោភបំពានឡើយ។

ក្នុងនាមជានាយកគម្រោង GIZ FABRIC លោក Marc Beckmann បានលើកឡើងនៅអំឡុងពេលថ្លែង សន្ទរកថាបិទថា "កិច្ចខិតខំប្រឹងប្រែងចាំបាច់ត្រូវមានកិច្ចសហការគ្នា និងហើយត្រូវបែងចែកការទទួល ខុសត្រូវដើម្បីភាពជោគជ័យ" ដែលសង្កត់ធ្ងន់លើតម្រូវការវិធីសាស្ត្ររួមសម្រាប់កំណើនដោយចីរភាព នៅកម្ពុជា ជាពិសេស ចំពោះមូលដ្ឋានច្បាប់ថ្មីស្តីពីការពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដែលនឹងមាន ខាងមុខនោះ។ ការទប់ស្កាត់ការបៀតបៀនផ្លូវភេទ ការបង្កើតកន្លែងធ្វើការប្រកបដោយសុវត្ថិភាព និង ការកែលម្អសុខុមាលភាពកម្មករគឺជាសមាសធាតុសំខាន់នៃធុរកិច្ចដែលមានទំនួលខុសត្រូវ។

កិច្ចប្រជុំនេះគឺជាជោគជ័យដ៏សំខាន់មួយ ហើយមជ្ឈមណ្ឌល RBH នៃសភាពាណិជ្ជកម្មអឺរ៉ុប សូមថ្លែង អំណរគុណចំពោះវាគ្មិន និងគណៈកម្មាធិការវិជ្ជ័យទាំងអស់ដែលបានចូលរួមចំណែកដ៏មានតម្លៃនេះ។

**អំពីសភាពាណិជ្ជកម្មអឺរ៉ុបប្រចាំនៅកម្ពុជា**

**សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា** (EuroCham Cambodia) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ2011 ដោយ សមាគមធុរកិច្ចបារាំង អាល្លឺម៉ង់ និងអង់គ្លេសនៅកម្ពុជាដើម្បីបំពេញមុខងារសភាផ្លូវការនៃសហគមន៍ ធុរកិច្ចអឺរ៉ុបនៅព្រះរាជាណាចក្រកម្ពុជា។ ចាប់តាំងពីពេលនោះមក សមាជិកសភាពាណិជ្ជកម្មអឺរ៉ុប បានកើនចំនួនដល់ជាង 300 និង 5 គណៈកម្មាធិការ ដែលមានប្រទេសអឺរ៉ុបចំនួន 11។ **សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា** មានសកម្មភាពស្ទួលលើកកម្ពស់ គាំទ្រ និងតំណាងឱ្យសមាជិករបស់ខ្លួន និង ផលប្រយោជន៍ធុរកិច្ចអឺរ៉ុបដោយសហការជាមួយរាជរដ្ឋាភិបាលកម្ពុជាដោយមានគោលបំណងធ្វើឱ្យ ដំណើរការធុរកិច្ច និងបរិយាកាសវិនិយោគកាន់តែប្រសិទ្ធភាព និងទទួលបានផ្លែផ្កាសម្រាប់ទាំងអស់គ្នា។

សកម្មភាពសំខាន់ៗរបស់សភាពាណិជ្ជកម្មអឺរ៉ុបមានដូចខាងក្រោម

- ពិគ្រោះយោបល់ និងតស៊ូមតិចំពោះបញ្ហាសំខាន់ៗដែលមានទាក់ទងនឹងការធ្វើធុរកិច្ចនៅកម្ពុជា។
- ជំរុញឱ្យមានការវិនិយោគមកប្រទេសកម្ពុជា។
- ធ្វើការកែលម្អការទទួលបានធុរកិច្ចអឺរ៉ុបមកទីផ្សារកម្ពុជា និងពីទីផ្សារកម្ពុជាទៅទីផ្សារអឺរ៉ុប និងសម្របសម្រួលធុរកិច្ចរវាងសហគ្រាសខ្នាតតូច និងមធ្យមកម្ពុជា និងរដ្ឋជាសមាជិកអឺរ៉ុប។
- ផ្តល់សេវាទាក់ទងនឹងសេដ្ឋកិច្ច ច្បាប់ បច្ចេកទេស ហិរញ្ញវត្ថុ ទីផ្សារ និងបញ្ហាផ្សេងទៀតនៅអឺរ៉ុប និងកម្ពុជា និងព័ត៌មានជាក់លាក់អំពីឧស្សាហកម្មដល់វិនិយោគិន។
- លើកកម្ពស់អត្តសញ្ញាណធុរកិច្ចអឺរ៉ុបកាន់តែរឹងមាំជាមួយសហគមន៍ធុរកិច្ចកម្ពុជា។
- សហការជាមួយភាគីពាក់ព័ន្ធកម្ពុជាក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចកម្ពុជាប្រកបដោយបរិយាបន្ន និងនិរន្តភាព។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

លោកស្រី Sara Monti មន្ត្រីសម្របសម្រួលជាន់ខ្ពស់នៃមជ្ឈមណ្ឌលធុរកិច្ចដែលមានទំនួលខុសត្រូវ តាមរយៈអ៊ីមែល៖ rbh@eurocham-cambodia.org

***

**<u>អំពីអង្គការសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (អង្គការ GIZ)</u>**

អង្គការសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (អង្គការ GIZ) គឺជាអង្គការផ្តល់ សេវាផ្នែក កិច្ចសហប្រតិបត្តិការអន្តរជាតិឈានគេមុខមួយ។ ក្នុងនាមជាសហគ្រាសសហព័ន្ធ យើងគាំទ្រដល់ក្រសួងកិច្ចសហប្រតិបត្តិ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ) សហព័ន្ធអាល្លឺម៉ង់ដើម្បីសម្រេច គោលបំណងរបស់ខ្លួនក្នុងផ្នែកកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការអភិវឌ្ឍដោយចីរភាព។ យើងក៏ចូលរួមក្នុងការងារអប់រំជាលក្ខណៈអន្តរជាតិនៅជុំវិញពិភពលោកផងដែរ។ គម្រោងរបស់អង្គការ GIZ ដែលមានឈ្មោះថា

“ការជំរុញ និងលើកកម្ពស់ធុរកិច្ចដោយចីរភាព និងការអនុវត្តឧស្សាហកម្មដោយមានទំនួលខុសត្រូវក្នុងឧស្សាហកម្មសម្លៀកបំពាក់” (FABRIC) នៅកម្ពុជា នឹងលើកឡើងអំពីចីរភាពក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថាន ដោយមានវិធានការគ្រប់ជ្រុងជ្រោយបន្ថែមទៀតឱ្យវិស័យឯកជនចូលរួមក្នុងសកម្មភាពគម្រោងនេះ។ គម្រោងក៏កំពុងធ្វើការងារក្នុងប្រទេសបង់ក្លាដេស កម្ពុជា មីយ៉ាន់ម៉ា ប៉ាគីស្ថាន វៀតណាម និងសហការជាមួយតួអង្គនានានៅក្នុងប្រទេសចិនដោយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់តំណាងធុរកិច្ច ស្ថាប័នរដ្ឋាភិបាល សង្គមស៊ីវិល និងសហជីពការងារដើម្បីកសាងឧស្សាហកម្មមួយនេះដែលផ្តល់ការងារមានគុណភាព ការពារបរិស្ថាន និងចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ច។

សូមទំនាក់ទំនង៖

លោកស្រី Kristin Sommer មន្ត្រីសម្របសម្រួលបរិស្ថាន និងពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ តាមរយៈ អ៊ីមែល៖ kristin.sommer@giz.de